# សេចក្តីថ្លែងការណ៍រួមរបស់អង្គការសង្គមស៊ីវិល

## ក្នុងឱកាសទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០២២ ខួបទី១១១

## ក្រោមប្រធានបទៈ "សកម្មភាពថ្ងៃនេះដើម្បីកិច្ចគាំពារសង្គមសម្រាប់ស្ត្រីអ្នកលក់ដូរតាមផ្លូវ និងនិរន្តភាពសមភាពយេនឌ័រ"

ទិវាអន្តរជាតិនារី ជាទិវាជាសកលដែលមហាសន្និបាតអង្គការសហប្រជាជាតិប្រកាសជាទិវារបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិស្ត្រីនិងសន្តិភាពពិភពលោកនាឆ្នាំ១៩១១។ ជារៀងរាល់ឆ្នាំប្រទេសកម្ពុជាប្រារព្ធពិធីនេះឡើង ដើម្បីរំលឹក ការតស៊ូរបស់ខ្លួនដោយចម្រុះជាតិសាសន៍បើទោះមាន ភាសា ពណ៌ សម្បុរ វប្បធម៌ សេដ្ឋកិច្ច និងនយោបាយខុសគ្នាយ៉ាងណាក្តី ដើម្បីអោយមានសិទ្ធស្មើភាពគ្នាក្នុងសង្គម។ ទិវានេះគោលបំណងដើម្បីអំពាវនាវ និងផ្សព្វផ្សាយដល់មនុស្សគ្រប់រូប ទាំងបុរស ស្ត្រី និងភេទដទៃទៀត ទប់ស្កាត់ និងលុបបំបាត់ការរើសអើងគ្រប់រូបភាពចំពោះស្ត្រី និងកុមា។ ស្របពេលដែលកំពុងស្ថិតក្នុងកាលៈទេសៈមួយ ដែលនៅតែបន្តរើសអើស ការរំលោភសិទ្ធិសេរីភាព ការគេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច អំពើហិង្សារ និងចាប់ដាក់ពន្ធនាគារសម្រាប់ស្ត្រី និងគ្រួសាររបស់ពួកគេ ជាពិសេសពេលរីករាលដាលនៃជម្ងឺកូវីដ-១៩ ចាប់តាំងពីចុងឆ្នាំ ២០១៩ ។ ក្រៅពីការរាយការណ៍អំពីការធ្លាកចុះនូវសេដ្ឋកិច្ច ឃើញថាទាំងសិទ្ធិ និងសេរីភាពជាមូលដ្ឋានត្រូវបានរារាំង និងរឹតត្បិតគ្រប់រូបភាព ជាហេតុធ្វើឲ្យស្ថានភាពរស់នៅរបស់ស្ត្រីកាន់តែមានភាពលំបាកបន្ថែមមួយកម្រិតទៀត។

សម្រាប់មុខរបរលក់ដូរតាមដងផ្លូវជាអាជីវកម្មដ៏ធំសម្បើមនៅក្នុងប្រទេសកម្ពុជា ភស្តុតាងជាស្ថិតិបង្ហាញថាអ្នកលក់ដូរតាមដងផ្លូវក្នុងប្រទេសកម្ពុជាចំនួនរហូតដល់១,៦៧៣,៣៩០នាក់ ឬស្មើនឹង១០% នៃចំនួនប្រជាពលរដ្ឋសរុប។ យោងតាមការសិក្សារបស់អង្គការ Oxfam(ឆ្នាំ២០១៩) បង្ហាញថាអ្នកលក់ដូរតាមដងផ្លូវស្ត្រី ៧៥% ដែលស្មើ១០% នៃចំនួនប្រជាពលរដ្ឋសរុបនៅទីក្រុងភ្នំពេញ។ ទោះបីជាវិស័យនេះដើរតួនាទីសំខាន់រួមចំណែកបង្កើតមុខរបរ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមក៏ដោយ ក៏អ្នកលក់ដូរតាមដងផ្លូវ(ស្ត្រី) មិនទទួលបានការការពារដោយច្បាប់ ដែលបង្កើតឲ្យមានជាការយាយី កេងប្រវ័ញ្ចជាបន្តបន្ទាប់ និងកង្វះការទទួលបានអត្ថប្រយោជន៍កិច្ចគាំពារសង្គមផ្សេងៗ។ សំខាន់ជាងនេះទៀតពួកគេក៏កំពុងរងគ្រោះពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិមួយចំនួន មិនសូវមានអំណោយផល និងដែលគម្រាមកំហែងដល់ឱកាសបង្កើតប្រាក់ចំណូល និងការបង្កើនឯករាជ្យភាពផ្នែកសេដ្ឋកិច្ចរបស់ពួកគេផងដែរ។ កង្វះទីតាំងលក់ដូរសមរម្យ បានបង្កើតឲ្យមានការរំលោភបំពាន និងការកេងប្រវ័ញ្ចជាប្រព័ន្ធមកលើអ្នកលក់ដូរតាមដងផ្លូវ (ដែលភាគច្រើនជាស្ត្រី) នៅទូទាំងប្រទេសកម្ពុជា។ យោងតាមទិន្នន័យស្រាវជ្រាវបានបង្ហាញថា ៤៩.៥៩% គឺជាស្ត្រីអ្នកលក់ដូរតាមដងផ្លូវ ខៈណៈមាន១៨.៤៤% ជាអ្នកលក់ដូរចល័ត ប៉ុន្តែមានតែប្រមាណជា ១១.៩៣% ដែលមានទីតាំងលក់ដូរនៅក្នុងផ្សារ។ ហើយដើម្បីរក្សាបាននូវកន្លែងលក់ដូរ និងការការពារពីអាជ្ញាធរ អ្នកលក់ដូរតាមដងផ្លូវ (ភាគច្រើនជាស្ត្រី) ទាំងនោះត្រូវសូកប៉ាន់នគរបាល សន្តិសុខផ្សារ និងបុគ្គល ដែលពាក់ឯកសណ្ឋានស៊ីវិល និងមិនស្គាល់អត្តសញ្ញាណ។ តាមការស្រាវជ្រាវបង្ហាញថាប្រមាណ ៥៤.១០% បានបង់ប្រាក់ចន្លោះពី៥០០ ទៅ១,០០០ រៀលក្នុងមួយថ្ងៃ។ ឯអ្នកដែលបង់ប្រាប់ចន្លោះពី១,១០០ ទៅ២,០០០រៀល ក្នុងមួយថ្ងៃ ជាមធ្យម មានប្រមាណជា ២២.៩២%។ បញ្ហាមួយចំនួនទៀតដូចជា មិនទទួលបានគ្រប់គ្រាន់នៅឡើយនូវកិច្ចគាំពារសង្គម ដូចជាមិនទទួលបានប័ណ្ណមូលនិធិសមធម៌ របបសន្តិសុខសង្គមនិងច្បាប់ស្តីពីរបបសន្តិសុខសង្គម មិនទាន់បានអនុវត្តន៍ក្នុងការផ្តល់ប្រយោជន៍មកដល់ពួកគេនៅឡើយ។ ជាក់ស្តែងក្នុងស្ថានភាពកូវីត-១៩ នេះអ្នកលក់ដូរតាមដងផ្លូវទទួលបានការគាំពារពីសង្គមតាមរយៈប្រព័ន្ធជំនួយសង្គម ក្នុងការផ្ទេរសាច់ប្រាក់ និងការឧបត្ថម្ភផ្សេងៗពីអាជ្ញាធរដ្ឋ ប៉ុន្តែមានចំនួនតិចតួច

ប៉ុណ្ណោះ។ បញ្ហាមិនទាន់មានមជ្ឈមណ្ឌលសម្រាប់ផ្ញើរកូនតូចៗរបស់ពួកគេ ឬទារកដ្ឋាន មិនទាន់មានសុវត្ថិភាពក្នុងការប្រកបមុខរបរអាជីវកម្ម និងប្រឈមនឹងការដេញចេញពីកន្លែងលក់ដូរជាដើម។ ការវិនិយោគដើម្បីអភិវឌ្ឍន៍ បណ្ដាលអោយបាត់បង់កន្លែងប្រកបមុខរបរអាជីវកម្ម គ្មានកន្លែងលក់ដូរសមរម្យ គ្មានអនាម័យ ប៉ះពាល់សុខភាព ការប្រើអំពើហឹង្សារនៅពេលចុះរៀបចំសណ្ដាប់ធ្នាប់ និងការចាប់ឥវ៉ាន់របស់អ្នកលក់ដូរតាមដងផ្លូវ ។

**ក្នុងគោលបំណងដើម្បីធ្វើឲ្យប្រសើរឡើងនូវកិច្ចគាំពារសង្គមសម្រាប់អ្នកលក់ដូរតាមដងផ្លូវ និងនិរន្តភាពសមភាពយេនឌ័រនៅកម្ពុជា ក្រុមអង្គការសង្គមស៊ីវិល និងសមាគម សូមស្នើដល់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងដែលពាក់ព័ន្ធមេត្តាពិចារណា ផ្ដល់កិច្ចអន្តរាគមន៍ និងដំណោះស្រាយដូចខាងក្រោម៖**

**កិច្ចអន្តរាគមន៍ទីមួយ៖** ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ គួរពិចារណាផ្ដល់នូវកិច្ចការពារផ្លូវច្បាប់ ដល់អ្នកលក់ដូរតាមដងផ្លូវ (ជាពិសេសស្ត្រី) ដើម្បីការពារពួកគេពីការរំលោភបំពាន និងការកេងប្រវ័ញ្ចជាលក្ខណៈប្រព័ន្ធ។ កិច្ចការពារនេះក៏មានសារៈសំខាន់ផងដែរ ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា ជាពិសេសគោលដៅទី៨ (ការងារសមរម្យ និងកំណើនសេដ្ឋកិច្ច) និងគោលដៅទី១០ (កាត់បន្ថយវិសមភាព)។

**កិច្ចអន្តរាគមន៍ទីពីរ៖** ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ច គួរចាត់ជាអាទិភាព និងផ្ដល់ការបណ្ដុះបណ្ដាលអំពីសុវត្ថិភាពចំណីអាហារ និងការលក់ដូរចំណីអាហារនៅតាមដងផ្លូវដល់អ្នកលក់ដូរតាមដងផ្លូវដើម្បីលើកកម្ពស់ឲ្យប្រសើរនូវសុវត្ថិភាពចំណីអាហារ និងសុខភាពសាធារណៈនៅកម្ពុជា។ អាជ្ញាធរគួរពិចារណាឲ្យមានគោលនយោបាយលើកទឹកចិត្ត និងបទដ្ឋានច្បាប់ដើម្បីលើកទឹកចិត្ត និងជម្រុញឲ្យមានការចូលរួមប្រកបដោយប្រសិទ្ធិភាព ស្មើភាពគ្នាមិនថាបុរស ឬស្ត្រី។ ក្រៅពីនេះចាំបាច់ណាស់ ក្នុងការធានាឲ្យមានការប្រមូល សំរាមប្រកបដោយប្រសិទ្ធិផល និងធានាឲ្យអ្នកលក់ដូរតាមចិញ្ចើមផ្លូវមានទឹកស្អាតប្រើប្រាស់ និងមានកន្លែងទុកដាក់សំរាមឲ្យបានត្រឹមត្រូវ។

**កិច្ចអន្តរាគមន៍ទីបី៖** សាលារាជធានីខេត្តក្រុង សូមពិចារណាផ្ដល់នូវទីតាំងលក់ដូរដ៏សមរម្យដល់អ្នកលក់ស្ត្រីអ្នកលក់ដូរតាមដងផ្លូវនៅតាមទីប្រជុំជន ឬតំបន់ទេសចរណ៍ អាជ្ញាធរគួរពិចារណារគោលនយោបាយល្អៗមួយចំនួននៅបណ្ដាប្រទេសជិតខាង ដោយសារតែប្រទេសទាំងនោះមានបញ្ហាប្រឈម ដែលមានលក្ខណៈដូចគ្នាទៅនឹងប្រទេសកម្ពុជាទាក់ទងនឹងការលក់ដូរតាមដងផ្លូវ។ វិធីសាស្ត្រដ៏ល្អនោះ គឺគម្រោងសាកល្បងដោយការរៀបចំទីតាំងដាក់លាក់ ឬយកផ្លូវណាមួយសម្រាប់ឲ្យអ្នកលក់ដូរតាមដងផ្លូវប្រកបរបររបស់ខ្លួន។ គម្រោងសាកល្បងនេះនឹងផ្ដល់ដល់អាជ្ញាធរនូវឱកាសក្នុងការវាយតម្លៃពីផលប៉ះពាល់ និងកាត់បន្ថយហានិភ័យ ដែលបង្កដោយគំនិតផ្ដួចផ្ដើមនេះ និងការអនុវត្តគោលនយោបាយក្នុងទ្រង់ទ្រាយធំ។ មានទីកន្លែងលក់ក្បែរគម្រោងការវិនិយោគអភិវឌ្ឍន៏ធំៗ និងធានាកុំអោយបាត់បង់ កន្លែងប្រកបមុខរបរអាជីវកម្មពួកគេ។

**កិច្ចអន្តរាគមន៍ទីបួន៖** ក្រសួងមហាផ្ទៃ សូមពិនិត្យមើលឡើងវិញនូវសេចក្ដីព្រាងច្បាប់ស្ដីពីសណ្ដាប់ធ្នាប់សាធារណៈ ដើម្បីធានាថា ពង្រាងច្បាប់នេះ ត្រូវបានតាក់តែងឡើងដើម្បីការពារផលប្រយោជន៍ និងពង្រឹងសិទ្ធិអំណាចរបស់ប្រជាពលរដ្ឋងាយរងគ្រោះ និងទន់ខ្សោយរបស់អ្នកលក់ដូរតាមដងផ្លូវ ជាពិសេសស្ត្រី កុមារ និងជនពិការ។ រដ្ឋាភិបាលតាមរយៈក្រសួងមហាផ្ទៃគួរតែពិចារណឲ្យមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យ និងការផ្សព្វផ្សាយជាសាធារណៈដើម្បីកសាងជំនឿចិត្តពីសាធារណៈជនការគោរពគ្នាទៅវិញទៅមក និងធានានូវការចូលរួមដ៏សកម្មពី(ស្ត្រី)អ្នកលក់ដូរតាមដងផ្លូវ ដែលជាឆ្អឹងខ្នងដ៏សំខាន់នៃសេដ្ឋកិច្ចរបស់ប្រទេសជាតិ។

**កិច្ចអន្តរាគមន៍ទីប្រាំ៖** ក្រសួងមហាផ្ទៃ ក្រសួងកិច្ចការនារី ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សូមពិចារណាពិនិត្យឡើងវិញនូវកម្មវិធីជំនួយសង្គ្រោះបន្ទាន់ចំពោះបញ្ហាកូវីដ-១៩ សម្រាប់អ្នកលក់ដូរតាមផ្លូវ (ជាពិសេសស្ត្រី)។ គួរពិចារណាកិច្ចអន្តរាគមន៍មួយ ដែលធ្វើឲ្យមានផលប៉ះពាល់ជាវិជ្ជមានរ

យៈពេលវែង ជាជាងគ្រាន់តែផ្ដល់ស្បៀង និងគ្រឿងទេស។ ដោយផ្អែកលើទិន្នន័យបែបបរិមាណវិស័យជំនួយសង្គ្រោះបន្ទាន់ ដែលចាំបាច់សម្រាប់អ្នកលក់ដូរតាមចិញ្ចើមផ្លូវ គឺការលើកលែងការបង់ពន្ធ-ភាស៊ី និងថ្លៃការពារនានា (ការទារលុយលើកន្លែងលក់ដូរតាមដងផ្លូវ) រួមទាំងការវិភាគទានគាំទ្រការបង់ថ្លៃជួលកន្លែងស្នាក់នៅរបស់ពួកគេជាដើម ជាពិសេសជម្រុញអោយមានការអនុវត្តឡើងវិញ នូវសារាចររបស់រាជរដ្ឋាភិបាល លេខ១១ ស.រ (ស្ដីពីការបញ្ឈប់ការទារភាស៊ីពីអ្នកលក់ដូរជាពិសេសលក់ (កញ្ច្រែង កញ្ជើ ល្អី )។

**កិច្ចអន្តរាគមន៍ទីប្រាំមួយ៖** ក្រុមប្រឹក្សាជាតិគាំពារសង្គម សូមផ្ដល់កិច្ចគាំពារសង្គមតាមរយៈការផ្ដល់នូវប័ណ្ណមូលនិធិសមធម៌ របបសន្តិសុខសង្គម និងធានាថាច្បាប់ស្ដីពីរបបសន្តិសុខសង្គម អនុវត្តន៍ក្នុងការផ្ដល់ប្រយោជន៍ដល់អ្នកលក់ដូរតាមផ្លូវ (ជាពិសេសស្ត្រី) ទទួលបានជំនួយជាសាច់ប្រាក់ និងការឧបត្ថម្ភផ្សេងៗទុនអាជីវកម្មខ្នាតតូចគ្រួសារ និងគួរមានមជ្ឈមណ្ឌលសម្រាប់ផ្ញើរកូនតូចៗរបស់ពួកគេ ឬមជ្ឈមណ្ឌលទារកដ្ឋានដើម្បីឱ្យឪពុកម្ដាយរបស់ពួកគេមានឱកាសរកប្រាក់ចំណូល ខណៈពេលដែលកុមារកំពុងស្នាក់នៅក្នុងមជ្ឈមណ្ឌលសម្រាប់ផ្ញើរកូនតូចៗ។

**កិច្ចអន្តរាគមន៍ទីប្រាំពីរ៖** រាជរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គួរពង្រឹងកិច្ចសហប្រតិបត្តិការបន្ថែមទៀតជាមួយធនាគារ និងមីក្រូហិរញ្ញវត្ថុ ដើម្បីផ្ដល់ប្រាក់កម្ចីដែលមានអត្រាការប្រាក់ទាប ដល់សហគ្រាសធុនតូច និងមធ្យម។ ជំនួយផ្នែកហិរញ្ញវត្ថុសម្រាប់សហគ្រាសធុនតូច និងមធ្យម អាចជួយដោះស្រាយផលប៉ះពាល់ និងមិនធ្វើអោយអាជីវកម្មត្រូវបានបិទ ចំពោះការគ្របដណ្ដប់ចាំបាច់ត្រូវរួមបញ្ចូលទាំងអាជីវកម្មដែលបានចុះបញ្ជី និងមិនបានចុះបញ្ជី។

**កិច្ចអន្តរាគមន៍ទីប្រាំបី៖** រាជរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គួរតែបន្តផ្សព្វផ្សាយព័ត៌មានអំពីផលប៉ះពាល់នៃមេរោគកូវីដ-១៩ និងវិធានការបង្ការសម្រាប់សហគ្រាសធុនតូច និងមធ្យម ដល់ប្រជាជននៅក្នុងសហគមន៍។ សំខាន់ជាងនេះទៅទៀត គួរតែផ្ដល់ព័ត៌មានបន្ថែម និងលើកទឹកចិត្តដល់សហគ្រាសធុនតូច និងមធ្យមក្នុងការចុះឈ្មោះជាអាជីវកម្មផ្លូវការ ដំណើរការចុះបញ្ជីគួរតែមានលក្ខណៈសាមញ្ញ និងងាយស្រួល។

*អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងដែលពាក់ពន្ធ័ មេត្តាទទួលយកនូវ ធាតុចូលសំខាន់ៗរបស់អង្គការសង្គមស៊ីវិល ដើម្បីពិចារណា ដោយសេចក្ដីអនុគ្រោះ។*

*សូមមេត្តា ទទួលនូវសេចក្ដីគោរពដ៏ខ្ពស់ខ្ពង់ អំពីយើងខ្ញុំ។*

**ថ្ងៃអង្គារ ៦កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥**
**រាជធានីភ្នំពេញ ថ្ងៃទី៨ ខែមីនា ឆ្នាំ២០២២**

***តំណាងសមាគម និងអង្គការសង្គមស៊ីវិលៈ***

១) សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA) ២) អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ(CPDD)
៣) វិទ្យាស្ថានតស៊ូមតិ និងគោលនយោបាយ (API)
៤) អង្គការអភិវឌ្ឍន៍សំឡេងសហគមន៍ (BCV) ៦) អង្គការទ្រទ្រង់ស្ត្រីខ្មែរ (COWS)
៥)អង្គការបណ្ដុះបណ្ដាលសហគមន៍ដើម្បីអភិវឌ្ឍ (CTOD) ៧) ខុមហ្វ្រែល (COMFREL)
៨) អង្គការសាមគ្គី (SAMAKY) ១០) ក្រុមទ្រទ្រង់ភូមិ (VSG)
៩) សម្ព័ន្ធគណនេយ្យភាពសង្គមកម្ពុជា (ANSA Cambodia) ១១) អង្គការយុវសន្តិភាព (YFP)
១២) អង្គការជំនួយជនបទ (RAO) ១៣) អង្គការជនពិការខេត្តក្រចេះ (KDPO)
១៥) សមាគម សំឡេងស្ត្រី សហគមន៍ (WCV-FM89.50) ១៤) អង្គការអភិវឌ្ឍន៍ស្ត្រី (AS)

***សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖***
*លោក វ៉ន់ ពៅ ប្រធានសមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ (IDEA)*
*ទូរសព្ទ៖ ០១២ ៥៣៤ ៧៩៦ / Email: vornpao@gmail.com*